# អ្នកជំនាញការអង្គការសហប្រជាជាតិស្នើយ៉ាងទទូចដល់ប្រទេសកម្ពុជា និងសហគមន៍អន្តរជាតិ ឲ្យពន្លឿនការកាត់សេចក្ដីមេដឹកនាំខ្មែរក្រហម

**ទីក្រុងហ្ស៊ឺណែវ** (១៤ មីនា ២០១៣) – អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី នៅថ្ងៃនេះ បានស្នើយ៉ាងទទូចដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ក.ត) រាជរដ្ឋាភិបាល អ្នកផ្ដល់ជំនួយអន្តរជាតិ និងអង្គការសហប្រជាជាតិ ឲ្យពន្លឿនការកាត់សេចក្ដីមេដឹកនាំខ្មែរក្រហម បន្ទាប់ពីមរណៈភាពរបស់លោក អៀង សារី ដែលជាជនជាប់ចោទមួយរូប ក្នុងចំណោមជនជាប់ចោទទាំងបួនរូប ដែលបច្ចុប្បន្នកំពុងស្ថិតនៅចំពោះមុខសាលាក្ដី ដែលគាត់បានទទួលមរណៈភាពក្នុងជន្មាយុ ៨៧ ឆ្នាំ។

"ខ្ញុំសូមអំពាវនាវដល់តួអង្គទាំងអស់ រាប់ទាំងសហគមន៍អន្តរជាតិទាំងមូល ឲ្យធ្វើការប្ដេជ្ញាចិត្តជាថ្មី ដើម្បីគាំទ្រដល់សាលាក្ដី អ.វ.ក.ត ឲ្យបន្តដំណើរដើម្បីបញ្ចប់ការងាររបស់ខ្លួនប្រកបដោយឯករាជ្យពេញលេញ" លោក ស៊ូប៊ែឌី បានគូសបញ្ជាក់យ៉ាងដូច្នេះ។ "យើងជំពាក់ការងារនេះ ចំពោះជនរងគ្រោះដែលនៅរស់ពីរបបខ្មែរក្រហម ក្រុមគ្រួសាររបស់ជនរងគ្រោះ និងសង្គមកម្ពុជាទាំងមូលដែលបន្តឈឺចាប់ពីផលប៉ះពាល់នៃរបបខ្មែរក្រហមរហូតមកដល់ថ្ងៃនេះ"។

លោកអៀង សារី ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និង ឧក្រិដ្ឋកម្មសង្គ្រាម ដែលកើតចេញពីមុខងាររបស់គាត់ក្នុងការដឹកនាំរបបខ្មែរក្រហម នៅក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ជាច្រើនទសវត្សរ៍កន្លងមកហើយ គាត់បានគេចវេះពីការកាត់សេចក្ដីលើកបទចោទប្រកាន់ទាំងនេះ។ ក្រោយពីបានរត់ចោលជួរខ្មែរក្រហមក្នុងឆ្នាំ១៩៩៦ មក គាត់បានរស់នៅក្នុងជីវភាពកក់ក្ដៅជាប្រជាជនធម្មតាម្នាក់នៅខេត្តប៉ៃលិនក្នុងប្រទេសកម្ពុជា រហូតដល់ថ្ងៃចាប់ខ្លួនគាត់ក្នុងឆ្នាំ២០០៧ តាមដីការបស់សាលាក្ដី អ.វ.ក.ត ។ គាត់ត្រូវបានឃុំខ្លួនចាប់ពីពេលនោះរហូតដល់គាត់ទទួលមរណៈភាព ខណៈដែលប្រពន្ធគាត់ និងសហជនជាប់ចោទមួយរូបក្នុងសំណុំរឿង០០២ គឺលោកស្រី អៀង ធារិទ្ធិ ដែលគាត់ត្រូវបានប្រកាសថាមានស្មារតីមិនសមស្របសំរាប់ធ្វើការកាត់សេចក្ដី។

"មរណៈភាពរបស់គាត់ នៅក្នុងពេលកំពុងដំណើរជំនុំជម្រះក្ដីនេះ មានន័យថា គាត់មិនទាន់ត្រូវបានសាលាក្ដីសំរេចសេចក្ដីស្ថាពរនៅឡើយទេ" អ្នករាយការណ៍ពិសេសបានមានប្រសាសន៍ដូច្នេះ។ " ប្រហែលជាដំណើរការស្វែងរកយុត្តិធម៌នៅក្នុងករណីនេះ មានការយឺតយ៉ាវពេក ប៉ុន្តែគាត់ត្រូវបង្ខំចិត្តឆ្លើយតបចំពោះការចោទប្រកាន់ដ៏អង់អាចប្រឆាំងនឹងគាត់នៅក្នុងតុលាការបើកចំហរមួយ។ ប្រព័ន្ធតុលាការមួយ បានចាប់ផ្ដើមធ្វើការលើសំណុំរឿងរបស់គាត់ សូម្បីតែក្រោយពីហេតុការណ៍បានកើតឡើងរយៈពេល ៣០ ឆ្នាំហើយក្ដី។ នេះគឺដោយសារតែការតស៊ូស្វិតស្វាញរបស់ប្រជាជនជាច្រើន ដែលភាគច្រើនបំផុតគឺជាជនរងគ្រោះបាននាំឲ្យមានសាលាក្ដីនេះឡើង។

"យើងដឹងពីករណីដទៃទៀតនៃដំណើរការគណនីយភាពនៅជុំវិញពិភពលោកថា បើទោះជាសាលក្រមមួយនៅមិនទាន់បានសំរេចជាស្ថាពរក្តី ក៏ការពិតដែលថាការមើលឃើញមុខគ្នារវាងលោក អៀង សារី និងចុងចោទទាំងឡាយ នឹងបានផ្តល់ភាពកត់ក្តៅក្នុងកំរិតខ្លះដល់ជនរងគ្រោះដែលនៅរស់ពីរបបខ្មែរក្រហម ក្រុមគ្រួសារជនរងគ្រោះ និងសង្គមកម្ពុជាទាំងមូលដែលបន្តឈឺចាប់ពីផលប៉ះពាល់នៃរបបខ្មែរក្រហមរហូតមកដល់ថ្ងៃនេះ" លោក ស៊ូប៊ែឌី បានកត់សំគាល់ដូច្នេះ។

*ចប់*

*លោកសាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូប៊ែឌី ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩។ ក្នុងនាមជាអ្នករាយការណ៍ពិសេស លោកមិនចំណុះរដ្ឋាភិបាល ឬអង្គការណាមួយឡើយ ហើយបំរើការក្នុងសមត្ថភាពបុគ្គលលោកផ្ទាល់ ។ បច្ចុប្បន្នលោកគឺជាសាស្ត្រាចារ្យផ្នែកនីតិអន្តរជាតិនៃសាកលវិទ្យាល័យលីដស៍ ចក្រភពអង់គ្លេស។*

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រប្រទេស – កម្ពុជា*
[http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx](http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx)

*សំរាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ**សូមមេត្តាទាក់ទងមកឈ្មោះ Olga Nakajo តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩២៨ ៩៣៤៨ / អ៊ីម៉ែល [onakajo@ohchr.org](mailto:onakajo@ohchr.org)) ឬសរសេរមកកាន់ [onakajo@ohchr.org](mailto:onakajo@ohchr.org))*

*សំរាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមមេត្តាទាក់ទងមកឈ្មោះ Xabier Celaya សិទ្ធិមនុស្ស អ.ស.ប – អង្គភាពព័ត៌មាន តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ / អ៊ីម៉ែល xcelaya@ohchr.org)*

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើងតាមរយៈព័ត៌មានសង្គម ៖**

ហ្វេសប៊ុក៖ [https://www.facebook.com/unitednationshumanrights](https://www.facebook.com/unitednationshumanrights)
ទ្វីតធឺ៖ [http://twitter.com/UNrightswire](http://twitter.com/UNrightswire)
ហ្គោហ្គឺល៖ **Google+** gplus.to/unitednationshumanrights
យូធូប៖ [http://www.youtube.com/UNOHCHR](http://www.youtube.com/UNOHCHR)
រឿង ៖ [http://storify.com/UNrightswire](http://storify.com/UNrightswire)

ឆែកមើលឧបសម្ព័ន្ធសិទ្ធិមនុស្សជាសកល ៖ [http://uhri.ohchr.org/en](http://uhri.ohchr.org/en)